អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក
## ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៦

អ.វ.ត.ក មានក្តីសោមនស្សរីករាយដោយទទួលបាននូវការប្រកាសពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលបញ្ជាក់អះអាងពីការជ្រើសតាំងរបស់ខ្លួន ចំពោះមន្ត្រីតុលាការថ្នាក់ជាតិ និងអន្តរជាតិសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ។

សេចក្តីសម្រេចនេះបញ្ជាក់ពីព្រឹត្តការណ៍សំខាន់ដែលបានរំពឹងទុកយ៉ាងមុតមាំចំពោះអត្ថិភាពនៃ អ.វ.ត.ក និងបញ្ជូនសញ្ញាយ៉ាងច្បាស់ដល់ប្រជាជនកម្ពុជា និងសមាជិកនៃសហគមន៍អន្តរជាតិថា អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះដំណើរការរបស់តុលាការនេះ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានប្រឈមនឹងភារកិច្ចដ៏លំបាក នៅក្នុងការជ្រើសរើសបេក្ខជនមកពីក្នុងចំណោមបេក្ខភាពដែលមានលក្ខណៈសម្បត្តិខ្ពស់ជាច្រើនរូប។ ចំណេះដឹងលើច្បាប់ជាតិ និងអន្តរជាតិ ប្រវត្តិសាវតានៃអាជីពការងារ ចរិតលក្ខណៈប្រកបដោយសីលធម៌ខ្ពស់ និងភាពស៊ាំនឹងច្បាប់មនុស្សធម៌ និងច្បាប់សិទ្ធិមនុស្ស នឹងត្រូវបានយកមកពិចារណា មុននឹងធ្វើការសម្រេចជាចុងក្រោយណាមួយ។

សម្រាប់តួនាទីខាងភាគីអន្តរជាតិវិញ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានពិចារណាទៅលើបញ្ជីឈ្មោះអ្នកដែលបានជ្រើសតាំង ដែលត្រូវបានផ្តល់ជូនដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ក្នុងនោះរួមមានអ្នកដែលមានជំនាញវិជ្ជាជីវៈច្បាប់ជ្រៅជ្រះ មកពីបណ្តាប្រទេសជាច្រើន។ តួនាទីរបស់ភាគីជាតិតម្រូវឲ្យមានការស៊ើបអង្កេតហ្មត់ចត់ទៅលើវិជ្ជាជីវៈ សុចរិតភាព និងភាពមិនលម្អៀងរបស់បេក្ខជននីមួយៗ។

អ.វ.ត.ក ជឿជាក់ថា ការជ្រើសរើសនេះនឹងធានាថា កិច្ចការរបស់អង្គជំនុំជម្រះវិសាមញ្ញនឹងឆ្លើយតបទៅនឹងបទដ្ឋានអន្តរជាតិ។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះអ្នកជំនាញច្បាប់ជាតិ និងអន្តរជាតិទាំងអស់ ដែលបានបញ្ជូនឈ្មោះរបស់ពួកគាត់សម្រាប់ការពិចារណានេះ និងសូមស្វាគមន៍យ៉ាងកក់ក្តៅដល់អ្នកដែលត្រូវបានជ្រើសតាំងឲ្យចូលរួមបំពេញកិច្ចការដ៏សំខាន់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

-ចប់-